*Anta GUISSE* *Arthur VERCKEN*

**គង់ សំអុន**

**មេធាវី**

ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Nov-2014, 08:58
CMS/CFO: Sann Rada

ប៉ារីស និងភ្នំពេញ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៤

អង្គជំនុំជម្រះសាលាដំបូង អ វ ត ក
ផ្លូវជាតិលេខ ៤ ចោមចៅ ខណ្ឌដង្កោ
ប្រអប់សំបុត្រ ៧១
ភ្នំពេញ កម្ពុជា

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព

យើងខ្ញុំបានទទួលសេចក្តីសម្រេចរបស់អស់លោក E320/2 ចុះថ្ងៃទី២១ ខែវិច្ឆិកា ដែលមានចំណងជើងថា “សេចក្តីសម្រេចស្តីពីការចាត់តាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់ ខៀវ សំផន”។

យើងខ្ញុំត្រូវបានចាត់ងតាំងដោយលោក ខៀវ សំផន តាមរយៈអង្គភាពគាំពារការការពារក្តី តាំងពីមុនពេលដែលអស់លោកចៅក្រមចាត់តាំងយើងខ្ញុំនេះទៅទៀត។ នៅពេលធ្វើការចាត់តាំងលើកទីមួយនេះ យើងខ្ញុំបានចុះកិច្ចសន្យាជាមួយអង្គការសហប្រជាជាតិ ជាកិច្ចសន្យាតំណាងផ្នែកច្បាប់ ដែលតម្រូវឲ្យយើងខ្ញុំបម្រើ និងការពារផលប្រយោជន៍របស់កូនក្តីឲ្យបានស្មោះត្រង់បំផុតជានិច្ច។ លក្ខខណ្ឌនេះ មាននៅក្នុងបទបញ្ញត្តិជាតិរបស់គណៈមេធាវីរៀងៗខ្លួនរបស់ពួកយើង ក៏ដូចជាក្នុងបទបញ្ញត្តិអន្តរជាតិ ដូចដែលយើងខ្ញុំបានលើកឡើងក្នុងកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី២៨ ខែតុលាឆ្នាំ២០១៤។

ក្នុងសំណេរ និងបទអន្តរាគមន៍ទាំងអស់របស់មេធាវីការពារក្តីលោក ខៀវ សំផន យើងខ្ញុំតែងតែចង្អុលបញ្ជាក់ថា គោលជំហររបស់ខ្លួនចង់ធ្វើការលើបណ្តឹងសារទុក្ខតែមួយទៅតាមពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ឲ្យ គឺជាគោលជំហរដែលយើងខ្ញុំអនុវត្តក្នុងនាមជាមេធាវី។

CETC - Bureau 102
e-mail : anta.guisse@wanadoo.fr - a.vercken.cetc@gmail.com

លោក ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្តន្ទាទោស ហេតុនេះ លោកមានសិទ្ធិធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទៀត។ ក្នុងបរិបទនៃនីតិវិធីច្រើនក្នុងពេលតែមួយ ដូចដែលអង្គជំនុំជម្រះបានសម្រេចនេះ លោក ខៀវ សំផន បានជ្រើសយកការធ្វើការលើនីតិវិធីមួយដែលអាចអនុញ្ញាតឲ្យមានការផ្លាស់ប្តូរសាលក្រមនេះបានក្នុងការការពារក្តីរបស់គាត់ ហើយដែលចិរវេលាសម្រាប់នីតិវិធីមួយនោះ វាកំពុងតែបន្តទៅមុខ។

វាជាជម្រើសយុទ្ធសាស្ត្រមួយ ដែលមិនមែនធ្វើឲ្យខាតពេលវេលា ឬក៏រំខានដល់នីតិវិធីអ្វីឡើយ។ នៅពេលដែលអស់លោកចៅក្រម បដិសេធសំណើរបស់យើងទាំងអស់ ក្នុងន័យនេះអស់រយៈពេលមួយឆ្នាំហើយ ដែលអស់លោកបាន ដាក់កូនក្តីរបស់យើងខ្ញុំ និងយើងខ្ញុំក្នុងស្ថានភាពបង្ខំជាន់គ្នានេះ យើងខ្ញុំសម្រេចចិត្តថាពេលនេះនឹងប្រមូលផ្តុំការងារលើបណ្តឹងសាទុក្ខ ដែលជាមធ្យោបាយតែមួយគត់របស់លោក ខៀវ សំផន ដើម្បីជំទាស់នឹងសេចក្តីសម្រេចមួយដែលផ្តន្ទាទោសដាក់ពន្ធនាគារគាត់មួយជីវិត។ ដូចលោកបានជ្រាបច្បាស់ហើយ បណ្តឹងសាទុក្ខនេះ សំខាន់ខ្លាំងណាស់សម្រាប់រូបគាត់ និងការការពារក្តីរបស់គាត់ ដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនឹងមានឥទ្ធិពលលើ សំណុំរឿង ០០២/២។ ជាពិសេសលើការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់គាត់។

ក្នុងនាមយើងជាមេធាវីរបស់លោក ខៀវ សំផន យើងខ្ញុំបានប្រកាសជាសាធារណៈអំពីការយល់ព្រមរបស់យើងជាមួយនឹងការវិភាគនេះ ដោយយើងយល់ថា វាជាអាទិភាពនៃការពារប្រយោជន៍របស់កូនក្តី។ ហេតុនេះហើយទើបយើងគោរពតាមការណែនាំរបស់គាត់។ ប្រសិនបើយើងមិនយល់ស្របតាមជំហររបស់គាត់ទេនោះ ឬបើយើងយល់ថា វាមិនសមរម្យទេនោះ យើងគួរតែបដិសេធការណែនាំរបស់កូនក្តី ហើយសុំលាឈប់ព្រោះថា ក្នុងសីលធម៌វិជ្ជាជីវៈមេធាវី មេធាវីម្នាក់មិនអាចធ្វើអ្វីផ្ទុយនឹងបំណងរបស់កូនក្តីខ្លួនបានឡើយ លើកលែងការណែនាំរបស់កូនក្តីនោះផ្ទុយនឹងសម្បថរបស់យើង។

នៅកថាខណ្ឌ ១៧ នៃសេចក្តីសម្រេចចុះថ្ងៃទី ២១ ខែវិច្ឆិកា លោកអះអាងថា៖

> អង្គជំនុំជម្រះយល់ឃើញថា ការរក្សាទុកមេធាវីបច្ចុប្បន្ន ដោយចាត់តាំងពួកគាត់ឲ្យធ្វើជាមេធាវីដែលចាត់តាំងដោយតុលាការ ប៉ុន្តែមិនឲ្យពួកគាត់គោរពតាមការណែនាំរបស់ជនជាប់ចោទមិនឲ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដែលជាការគំហិតដែលប៉ះពាល់តិចតួចបំផុតដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការជ្រើសរើសមេធាវីដែលអាចចូលរួមសវនាការបាន។ អង្គជំនុំជម្រះយល់ឃើញទៀតថា ប្រការនេះមានលក្ខណៈសមាមាត្រទៅនឹងគោលបំណងក្នុងការសម្រេចឲ្យបាននូវកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។

តាមរយៈកថាខណ្ឌនេះ សម្រាប់អស់លោក ការចាត់តាំងថ្មីរបស់អង្គជំនុំជម្រះនេះ ជាការចាត់តាំងមួយដែលខុសពីអ្វីដែលយើងបានយល់ព្រម នៅក្នុងពេលចុះហត្ថលេខាលើកិច្ចសន្យាជាមួយនឹងអង្គការសហប្រជាជាតិ ហើយជាលទ្ធផល វាអាចនឹងរារាំងយើងខ្ញុំមិនឱ្យគោរពតាមសេចក្ដីណែនាំរបស់កូនក្ដីយើងខ្ញុំ។ តាមពិតទៅ បើតាមទស្សនៈយើងខ្ញុំ សេចក្ដីសម្រេចនេះ គឺមានគោលដៅបង្ខំយើងខ្ញុំឱ្យបំពានលើកាតព្វកិច្ចវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ពីព្រោះសេចក្ដីសម្រេចនេះមានបំណងបង្ខំយើងខ្ញុំឱ្យធ្វើអ្វីដែលយើងខ្ញុំវាយតម្លៃថាផ្ទុយពីផលប្រយោជន៍កូនក្ដីរបស់យើងខ្ញុំ។ យើងសូមបដិសេធ។

មិនត្រឹមតែមានទំនាស់ផលប្រយោជន៍ដ៏ជាក់ច្បាស់ រវាងការចាត់តាំងទីពីរដែលមានគោលបំណងជម្រុញឱ្យយើងខ្ញុំបំពេញការងារប្រឆាំងនឹងការណែនាំរបស់កូនក្ដីយើងខ្ញុំ និងករណីយកិច្ចប្រកបដោយភាពស្មោះត្រង់ចំពោះកូនក្ដីប៉ុណ្ណោះទេ តែជាពិសេស វាក៏ជាបញ្ហាប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ឯករាជ្យភាពនៃមេធាវីការពារក្ដី ចំពោះមុខតុលាការ។ យើងខ្ញុំសូមរក្សាទស្សនៈដែលថា ការបង្ខំជនជាប់ចោទឱ្យកាត់ចោលថិរវេលាកំណត់របស់ខ្លួន សម្រាប់បណ្ដឹងសាទុក្ខដោយបង្ខំជនជាប់ចោទ ក្នុងពេលទន្ទឹមនឹងគ្នានោះ ឱ្យចូលរួមសវនាការ និងរៀបចំសវនាការ គឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានពេលវេលាចាំបាច់សម្រាប់រៀបចំការការពារក្ដីរបស់ខ្លួន។

យុត្តិស្ដាស្ត្រដែលលោកប្រធានបានលើកឡើងនៅក្នុងសេចក្ដីសម្រេច E320/2 មិនយោងទៅនឹងស្ថានភាពពិសេស និងមិនធ្លាប់កើតមាននេះឡើយ។

ម៉្យាងវិញទៀត យើងខ្ញុំក៏សូមរំឭកផងដែរថា មេធាវីម្នាក់ បើទោះជាទម្រង់នៃការចាត់តាំងបែបណាក៏ដោយ ក៏នៅតែស្ថិតក្រោមកាតព្វកិច្ចដូចៗគ្នា ហើយមេធាវីនោះត្រូវតែបម្រើដោយស្មោះត្រង់នូវផលប្រយោជន៍កូនក្ដីរបស់ខ្លួន ដោយគិតដល់ផលប្រយោជន៍កូនក្ដីមុនអ្វីៗទាំងអស់។

ចុងបញ្ចប់ យើងខ្ញុំសូមរំឭកពីគោលបំណងយើងខ្ញុំក្នុងការចូលរួមក្នុងសវនាការជាថ្មី ដរាបណាសារណាបណ្ដឹងសាទុក្ខត្រូវបានដាក់រួច។

សូមលោកប្រធាន និងអស់លោក លោកស្រីចៅក្រមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

**KONG Sam Onn** **Arthur VERCKEN** **Anta GUISSE**